**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

លេខ: ៣៧៥៩ មស.ក្រខ

ថ្ងៃពុធ ៤រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០២០

**សូមគោរពជូន**

**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន**

**កម្មវត្ថុ ៖** ស្តីពីការផ្តល់ផែនការក្របខណ្ឌជូនគ្រប់ក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០២១។

**យោង** ៖- ចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

- លិខិតលេខ១៩២៧ មស.ក្រខ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ ស្តីពីការជ្រើសរើសមន្ត្រីរាជការស៊ីវិល និងការអនុវត្តកម្មសិក្សា សម្រាប់ផែនការក្របខណ្ឌឆ្នាំ២០២០ របស់ក្រសួងមុខងារសាធារណៈ
- លិខិតលេខ៥៧៤៥ មស.ក្រខ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីផែនការក្របខណ្ឌឆ្នាំ២០២០ របស់ក្រសួងមុខងារសាធារណៈ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី** គ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាបថា រាជរដ្ឋាភិបាលបានកំណត់ចំនួនផែនការក្របខណ្ឌសម្រាប់ឆ្នាំ២០២១ ដោយត្រូវអនុវត្តដូចខាងក្រោម ៖

ក. ផែនការក្របខណ្ឌ មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីជាប់កិច្ចសន្យាប្រភេទផ្សេងទៀត

១. ចំពោះការជ្រើសរើសក្របខណ្ឌថ្មីឆ្នាំ២០២១ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តផ្អែកត្រឹមចំនួនផែនការក្នុងឆ្នាំ២០២០ ដែលបានផ្អាកកន្លងមកតែប៉ុណ្ណោះ លើកលែងក្រសួង ស្ថាប័នចំនួន ០៣ គឺក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងរាជបណ្ឌិតសភាកម្ពុជានៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានអនុវត្តការជ្រើសរើសរួចហើយ មិនអាចជ្រើសរើសក្របខណ្ឌថ្មីបន្ថែមក្នុងឆ្នាំ២០២១ ឡើយ។ ដោយឡែក ក្រសួង ស្ថាប័ន ដែលបានធ្វើការជ្រើសរើសមន្ត្រីក្របខណ្ឌមួយចំនួនរួចហើយក្នុងឆ្នាំ២០២០ អាចធ្វើការជ្រើសរើសចំនួនក្របខណ្ឌដែលនៅសល់តែប៉ុណ្ណោះ សម្រាប់ឆ្នាំ២០២១។

២. ការប្រឡងជ្រើសរើសនិងការអនុវត្តកម្មសិក្សា អាចចាប់ផ្តើមពី ខែមករា ឆ្នាំ២០២១ តទៅ ដោយត្រូវអនុវត្តខ្ជាប់ខ្ជួនតាមការណែនាំវេជ្ជសាស្ត្ររបស់ក្រសួងសុខាភិបាល ដើម្បីប្រយុទ្ធប្រឆាំងជំងឺកូវីដ ១៩។ ក្រសួង ស្ថាប័ន ត្រូវជូនដំណឹងអំពីការប្រឡងជ្រើសរើស អនុលោមតាមនីតិវិធីជាធរមាន និងខ្លឹមសារនៃលិខិតលេខ១៩២៧ មស.ក្រខ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ របស់ក្រសួងមុខងារសាធារណៈ។

៣. ចំពោះមន្ត្រីជាប់កិច្ចសន្យា ឆ្មាំទំនប់ប្រព័ន្ធធារាសាស្ត្រជាប់កិច្ចសន្យា គ្រូបង្រៀនពុទ្ធិកជាប់កិច្ចសន្យា គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរថ្នាក់ពីរពេល និងថ្នាក់គួបគ្រប់កម្រិត គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ និងគ្រូបង្រៀនជាប់កិច្ចសន្យាខ្មែរ-ឥស្លាម ដែលត្រូវផ្តល់ជូនក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០២១ គឺត្រូវអនុវត្តតាមចំនួនដែលបានផ្តល់ជូនក្នុងឆ្នាំ២០២០។



ផ្លូវវិក្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

ក្រសួងមុខងារសាធារណៈ សូមគោរពជូនភ្ជាប់នូវតារាងឧបសម្ព័ន្ធស្តីពីការផ្តល់ក្របខណ្ឌជូនក្រសួង ស្ថាប័ន ចំនួន ០១ច្បាប់។ ដោយឡែកសម្រាប់តារាងឧបសម្ព័ន្ធស្តីពីការបែងចែកមន្ត្រីជាប់កិច្ចសន្យា ឆ្មាំទំនប់ប្រព័ន្ធធារាសាស្ត្រជាប់កិច្ចសន្យា គ្រូបង្រៀនពុទ្ធិកជាប់កិច្ចសន្យា គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរថ្នាក់ពីរពេល និងថ្នាក់គួបគ្រប់កម្រិត គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ និងគ្រូបង្រៀនជាប់កិច្ចសន្យាខ្មែរ-ឥស្លាម ក្រសួងមុខងារសាធារណៈ នឹងផ្តល់ជូននៅពេលក្រោយ បន្ទាប់ពីការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ក្រសួងមុខងារសាធារណៈ សូមគោរពជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាបថា នៅពេលបើកឱ្យមានការប្រឡងប្រជែងសូមមេត្តារៀបចំជ្រើសរើសបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឱ្យចូលបម្រើការងារ ដើម្បីបំពេញមុខតំណែងដែលទំនេរ និងសេចក្តីត្រូវការដែលមានពិតប្រាកដនៅតាមអង្គភាពថ្នាក់ជាតិ មន្ទីរ និងអង្គភាពជំនាញនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងយកចិត្តទុកដាក់ដល់បេក្ខភាពជាជនពិការដែលមានសមត្ថភាពសមស្រប ២% នៃចំនួនក្របខណ្ឌសរុបរបស់សាមីក្រសួង ស្ថាប័ន ហើយគួរមានបេក្ខនារីជាប់ជាស្ថាពរពី ២០% ទៅ ៥០% នៃចំនួនក្របខណ្ឌដែលទទួលបានប្រចាំឆ្នាំ។

ទន្ទឹមនេះ សូម សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន មេត្តារៀបចំស្នើសុំមន្ត្រីតំណាងក្រសួងមុខងារសាធារណៈ ចូលរួមក្នុងដំណើរការប្រឡងឱ្យបានមុនពេលរៀបចំបង្កើតគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសប្រចាំឆ្នាំ ដើម្បីក្រសួងមុខងារសាធារណៈ មានលទ្ធភាពចូលរួមសហការចាប់តាំងពីដំណាក់កាលដំបូង។

សូម **សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី** មេត្តាជ្រាប និងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**រដ្ឋមន្ត្រី**

ហ៊ុំ សុខា

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

" ដើម្បីជូនជ្រាប "

-អគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ នៃក្រសួងមុខងារសាធារណៈ

-មន្ទីរមុខងារសាធារណៈ រាជធានី ខេត្ត

-មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត

" ដើម្បីសហការអនុវត្ត "

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
អគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ
នាយកដ្ឋានគ្រប់គ្រងក្របខ័ណ្ឌ

# តារាងឧបសម្ព័ន្ធ
# ស្ដីពី
# ការបែងចែកក្របខណ្ឌមន្ត្រីរាជការស៊ីវិល ជូនក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០២១

**យោង** ៖ លិខិតលេខ៣៧៥៩ មស.ក្រខ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការផ្តល់ផែនការក្របខណ្ឌជូនគ្រប់ក្រសួង ស្ថាប័ន របស់ក្រសួងមុខងារសាធារណៈ។

| ល.រ | ក្រសួង ស្ថាប័ន | ក្របខណ្ឌ | ផ្សេងៗ |
|---|---|---|---|
| ១ | ព្រះបរមរាជវាំង | ០៩ | |
| ២ | ទីស្តីការគណៈរដ្ឋមន្ត្រី | ២២ | |
| ២.១ | ទីស្តីការគណៈរដ្ឋមន្ត្រី(រាជបណ្ឌិតសភាកម្ពុជា) | ០០ | |
| ៣ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ១២ | |
| ៤ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ០០ | |
| ៥ | មហាផ្ទៃ ( ទីស្តីការក្រសួង ) | ៤០ | |
| ៥.១ | មហាផ្ទៃ (រដ្ឋបាលថ្នាក់ក្រោមជាតិ) | ១៧០ | |
| ៦ | ទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភានិងអធិការកិច្ច | ០៥ | |
| ៧ | ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ០០ | |
| ៨ | សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ៩៦ | |
| ៩ | ព័ត៌មាន | ២៤ | |
| ១០ | សុខាភិបាល | ១៣០០ | |
| ១១ | រ៉ែនិងថាមពល | ០៨ | |
| ១២ | ផែនការ | ០០ | |
| ១៣ | ពាណិជ្ជកម្ម | ៣៦ | |
| ១៤ | អប់រំ យុវជននិងកីឡា | ៣៦០០ | |
| ១៥ | កសិកម្ម រុក្ខាប្រមាញ់និងនេសាទ | ១៣៣ | |
| ១៦ | វប្បធម៌និងវិចិត្រសិល្បៈ | ៩៨ | |
| ១៧ | បរិស្ថាន | ១០ | |
| ១៨ | អភិវឌ្ឍន៍ជនបទ | ០០ | |
| ១៩ | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ០០ | |
| ២០ | ប្រៃសណីយ៍និងទូរគមនាគមន៍ | ៣៩ | |

| ល.រ | ក្រសួង ស្ថាប័ន | ក្របខណ្ឌ | ផ្សេងៗ |
|---|---|---|---|
| ២១ | ធម្មការនិងសាសនា (ទីស្តីការក្រសួង) | ០០ | |
| ២១.១ | ធម្មការនិងសាសនា (អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ) | | |
| ២២ | កិច្ចការនារី | ២០ | |
| ២៣ | សាធារណការនិងដឹកជញ្ជូន | ១៣៣ | |
| ២៤ | យុត្តិធម៌ (ទីស្តីការក្រសួង) | ០០ | |
| ២៤.១ | យុត្តិធម៌ (អគ្គនាយកដ្ឋានកិច្ចការតុលាការ) | ១៧៨ | |
| ២៥ | ទេសចរណ៍ | ១៤ | |
| ២៦ | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ០០ | |
| ២៧ | ធនធានទឹក និងឧតុនិយម (ទីស្តីការក្រសួង) | ២៨ | |
| ២៧.១ | ធនធានទឹក និងឧតុនិយម (អាជ្ញាធរទន្លេសាប) | | |
| ២៧.២ | ធនធានទឹក និងឧតុនិយម (គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា) | | |
| ២៨ | ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១៨ | |
| ២៩ | អង្គភាពប្រឆាំងអំពើពុករលួយ | ៧៥ | |
| ៣០ | មុខងារសាធារណៈ | ០៨ | |
| ៣១ | ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ៣០ | |
| ៣២ | គណៈកម្មការជាតិប្រឆាំងអំពើការវកម្ម | ០០ | |
| សរុប | | ៦១០៦ | |

ថ្ងៃអង្គារ ៣ រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០២០

**បានឃើញ និងពិនិត្យត្រឹមត្រូវ**

**អគ្គនាយក**

**យឿន សម្បត្តិ**

**អ្នកធ្វើតារាង**

**គង់ សុខក្តិភាព**

**បានឃើញ និងឯកភាព**

ថ្ងៃពុធ ៤ រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០២០

**ជ. រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

**យក់ ប៊ុនណា**